**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION**

# PRESS RELEASE

"**The Taste of Angkor**", a cookbook prepared and published by the Ministry of Foreign Affairs and International Cooperation as part of its cultural diplomacy, has been distinguished as the "**Best Asian Cookbook**" at the **Gourmand World Cookbook Awards 2021**. The award ceremony is currently being held in Paris from 29 November to 6 December 2021.

The Gourmand World Cookbook Awards was founded in 1995 by Edouard Cointreau with the goal of supporting culinary traditions from around the globe. Every year, they honour the best food and wine books as well as food television. In 2021, there were 198 countries entering the competition with a total submission of 4000 cookbooks.

The *Taste of Angkor,* which was unveiled on 18 January 2021 by **His Excellency Deputy Prime Minister Prak Sokhonn,** contains a selection of 38 recipes of Khmer dishes and desserts. Easy-to-follow detailed instructions, encompassing ingredient substitutions of Khmer ingredients that may be hard to source abroad, were the highlight of this artistic culinary book. The *Taste of Angkor*, which were provided for the use of Cambodian diplomats and to be presented as gifts to foreign dignitaries, is a great contribution of the Royal Government of Cambodia's advancement of its food and cultural diplomacy.

The Gourmand World Cookbook Awards 2021 is a fresh source of pride and honour for the Kingdom of Cambodia's efforts to get the world to know and truly appreciate the great legacy of Cambodia's thousand-year-old culinary heritage.

Food diplomacy is one of the cornerstones of the Ministry of Foreign Affairs and International Cooperation's Economic Diplomacy Strategy 2021-2023. The aim of the Strategy is to enhance Cambodia's prestige on the international stage and to contribute to the realisation of the Royal Government of Cambodia's vision for 2030 and 2050.

Phnom Penh, 01 December 2021

Address : N° 3, **Samdech HUN Sen** Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

សៀវភៅ "កេរ្តិ៍ដំណែលស្នាដៃម្ហូបខ្មែរ (The Taste of Angkor)" ដែលបានរៀបចំចងក្រងឡើងដោយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជ័យលាភីជា «សៀវភៅមុខម្ហូបអាស៊ីដែលល្អផ្តាច់គេ» (The Best Asian Cookbook) នៅក្នុងកម្មវិធី Gourmand World Cookbook Award 2021 ដែលប្រារព្ធធ្វើឡើងនៅទីក្រុងប៉ារីស ប្រទេសបារាំង ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១។

កម្មវិធី Gourmand World Cookbook Award ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដោយលោក Edouard Cointreau ក្នុងគោលបំណងលើកស្ទួយ និងផ្សព្វផ្សាយវប្បធម៌ម្ហូបអាហារទូទាំងសកលលោក។ នៅក្នុងឆ្នាំ២០២១នេះ មានការចូលរួមពីប្រទេសចំនួន ១៩៨ ដោយមានសៀវភៅសរុបចំនួន៤ ០០០ក្បាល ដែលត្រូវបានជ្រើសរើសមកប្រកួតប្រជែងនៅក្នុងព្រឹត្តិការណ៍នេះ។

សៀវភៅ "កេរ្តិ៍ដំណែលស្នាដៃម្ហូបខ្មែរ" ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ ដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ បានពិពណ៌នាយ៉ាងពិស្តារអំពីគ្រឿងផ្សំ មុខម្ហូប និងបង្អែមរបស់ខ្មែរ ចំនួន៣៨មុខផ្សេងគ្នា តាមរយៈវិធីចម្អិនងាយៗ និងងាយស្រួលរកគ្រឿងផ្សំនៅបរទេស សម្រាប់អ្នកការទូតកម្ពុជាប្រើប្រាស់ និងផ្តល់ជាវត្ថុអនុស្សាវរីយ៍ជូនភ្ញៀវបរទេស។

ការទទួលបានពានរង្វាន់ «សៀវភៅមុខម្ហូបអាស៊ីដែលល្អផ្តាច់គេ» នាពេលនេះ គឺជាមោទនភាពជាតិ និងជាសមិទ្ធផលដ៏ត្រចះត្រចង់ថ្មីមួយទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញវិស័យការទូតម្ហូបអាហារ សំដៅផ្សព្វផ្សាយឱ្យពិភពលោកបានស្គាល់កាន់តែច្បាស់ពីកេរ្តិ៍ដំណែល និងប្រណីតភាពនៃសិល្បៈម្ហូបខ្មែរ ដែលជាអត្តសញ្ញាណនៃអរិយធម៌ដ៏វិសេសវិសាលរបស់កម្ពុជា។

ការលើកតម្កើងវិស័យការទូតម្ហូបអាហារនេះ ជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានគោលដៅលើកស្ទួយកិត្យានុភាពជាតិ និងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការឈានទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០ និងឆ្នាំ២០៥០៕

ថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២១

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh